ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៣ សសរ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការចំរុះ សំរាប់សិក្សាវាយតំលៃ និងរៀបចំប្លង់មេលើកោះទាំងអស់ ដែលមានសក្តានុពលសេដ្ឋកិច្ច ដើម្បីធ្វើជាមូលដ្ឋានអោយក្រុមហ៊ុនវិនិយោគនានាដេញថ្លៃតាមផ្នែកនីមួយៗ ដែលមានចែងក្នុងប្លង់មេ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ១១២ អនក្រ.បក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០២ និងលេខ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤
- យោងអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តន៍ច្បាប់វិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យស្តីពីការធ្វើវិសោធនកម្មជាបន្តបន្ទាប់លេខ៥៣ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ១៩៩៩ និងលេខ១៣០ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១
- យោងស្មារតីអង្គប្រជុំ "ច្រកចេញ-ចូលតែមួយ" នៃក.អ.ក "គ.វ.ក" នាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៤ និងចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤
- តាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

www.pheakdeylaw.com

## សម្រេច

**ប្រការ១:** បង្កើតគណៈកម្មការចំរុះ ដែលមានសមាសភាពដូចខាងក្រោម ដើម្បីចុះធ្វើការសិក្សាលើកោះទាំងអស់ ដែលមានសក្តានុពលសេដ្ឋកិច្ច សំរាប់អោយក្រុមហ៊ុនវិនិយោគនានាដេញថ្លៃតាមផ្នែកនីមួយៗ ដែលមានចែងក្នុងប្លង់មេ :

| | | |
|---|---|---|
| ១- | ឯកឧត្តម **នុត ណារ៉ាង** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២- | ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៣- | ឯកឧត្តម **ជា សារ៉េហុង** រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៤- | ឯកឧត្តម **ថោង ខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៥- | ឯកឧត្តម **ត្រាំ អ៊ីវតឹក** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦- | ឯកឧត្តម **ស្រ៊ុន តារា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- | លោកជំទាវ **មាស ម៉ារ៉ិន** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៨- | ឯកឧត្តម **អ៊ិត ណារ៉ូឌី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩- | ឯកឧត្តម **មួង សៅខន** អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១០- | ឯកឧត្តម **នូ តៀង** អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ១១- | ឯកឧត្តម អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ | សមាជិក |
| ១២- | ឯកឧត្តម **ឌុយ ឆៅ** អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា | សមាជិក |
| ១៣- | លោក **ពត ណារិន** ប្រធាននាយកដ្ឋានវិភាគគំរោង និងការលើកទឹកចិត្ត នៃ"គ.វ.ក" | លេខាធិការ |

សមាជិកគណៈកម្មការទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន ក្នុងករណីប្រធានអវត្តមាន ។

**ប្រការ២:** គណៈកម្មការនេះ មានភារកិច្ចដូចតទៅ :

- សិក្សាស្រាវជ្រាវសក្តានុពលកោះទាំងអស់ ដើម្បីកំណត់មុខសញ្ញាជាអាទិភាពកោះមួយចំនួន ដែលអាចបំរើការវិនិយោគបាន។
- ចុះសិក្សាផ្ទាល់ដល់ទីតាំងកោះទាំងនោះ ដើម្បីរៀបចំប្លង់មេ "Master Plan" សំរាប់ដាក់ជូនផ្នែកឯកជនចូលរួមដេញថ្លៃវិនិយោគ ដោយចាប់ផ្តើមចុះសិក្សារៀបចំប្លង់មេលើកោះទន្សាយ ក្រុងកែបមុនគេ។
- កំណត់គោលនយោបាយ ស្តីពីការវិនិយោគលើកោះទាំងនោះ
- ធ្វើរបាយការណ៍ពីលទ្ធផលការងារជូន"ក.អ.ក" ដើម្បីដាក់ប្រជុំ"ច្រកចេញ-ចូលតែមួយ"ពិនិត្យ និងលើកមតិជូនសម្តេចសហប្រធាន"ក.អ.ក"ពិនិត្យ និងសំរេច ។

**ប្រការ៣:** គណៈកម្មការនេះ អាចប្រើប្រាស់កញ្ចប់ថវិការបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សំរាប់បេសកកម្មរបស់ខ្លួន និងមានការិយាល័យអចិន្ត្រៃយ៍តាំងនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាភិវឌ្ឍន៍កម្ពុជា សំរាប់អនុវត្តការងារ ។

www.pheakdeylaw.com

**ប្រការ៤:** សហប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី - សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់-រដ្ឋមន្ត្រីក្រសួងបរិស្ថាន-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល-រដ្ឋមន្ត្រីក្រសួងទេសចរណ៍-រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម-រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន-រដ្ឋមន្ត្រីគ្រប់ក្រសួង-គ្រប់ប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះតាមភារកិច្ចរៀងៗខ្លួនអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com